# ស្ថានភាពអតិផរណានៅខែវិច្ឆិកា ឆ្នាំ២០១៨

## ក/ អតិផរណាក្នុងប្រទេស

តាមប្រភពទិន្នន័យផ្លូវការពីវិទ្យាស្ថានជាតិស្ថិតិ (NIS) បានបង្ហាញថា សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅរាជធានីភ្នំពេញក្នុងខែវិច្ឆិកា បានថយចុះ **០,៤%** ធៀបនឹងខែមុន ប៉ុន្តែកើនឡើង **២,៥%** បើធៀបនឹងខែដូចគ្នាឆ្នាំមុន។

ក្នុងខែវិច្ឆិកា ឆ្នាំ២០១៨នេះ សន្ទស្សន៍ថ្លៃទំនិញភាគច្រើនមានការកើនឡើងធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះសន្ទស្សន៍ថ្លៃក្រុមទំនិញអាហារនិងភេសជ្ជៈមិនមែនជាតិស្រវឹងកើន ២,៣%, ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់កើន ៤,៧%, សម្លៀកបំពាក់និងស្បែកជើងកើន ២,៨%, ការដឹកជញ្ជូនកើន ២,៦% និងភោជនីយដ្ឋានកើន ៦,៣%។ **តាមរយៈទិន្នន័យក្នុងរយៈពេល ១១ខែ ឆ្នាំ២០១៨នេះ ស្ថានភាពបម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញមានអត្រាកំណើន ២,៥% ទាបជាង អត្រាកំណើនក្នុងអំឡុងពេលដូចគ្នាឆ្នាំ២០១៧ ដែលមានអត្រា ៣,០% ដោយសារការថមថយកំណើននៃសន្ទស្សន៍ថ្លៃក្រុមទំនិញម្ហូបអាហារក្នុងអំឡុងដើមឆ្នាំ២០១៨កន្លងទៅ បើទោះបីជាសន្ទស្សន៍ថ្លៃក្រុមទំនិញការដឹកជញ្ជូន (ប្រេងសាំង និងម៉ាស៊ូត) មានការកើនឡើងក៏ដោយ។**

តាមការធ្វើចំណោលដល់ខែធ្នូ ឆ្នាំ២០១៨[១] អតិផរណាប្រចាំឆ្នាំ (year on year) អាចនឹងមានអត្រា ២,៥% និងអតិផរណាមធ្យមប្រចាំឆ្នាំ (year average) អាចនឹងមានអត្រា ២,៥%។

| តារាង ១÷ បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញទាំង១២ក្រុម (%) | | |
|---|---|---|
| | ធៀបនឹងខែមុន | ធៀបនឹង១ឆ្នាំមុន |
| **មុខទំនិញគ្រប់មុខ** | **-០,៤** | **+២,៥** |
| ១-អាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង | -០,៥ | +២,៣ |
| ២-ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ | +១,៤ | +៤,៧ |
| ៣-សម្លៀកបំពាក់និងស្បែកជើង | -០,២ | +២,៨ |
| ៤-ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន | -០,១ | +១,៧ |
| ៥-គ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់ | +០,២ | +០,៧ |
| ៦-សុខាភិបាល | +០,១ | +១,៨ |
| ៧-ការដឹកជញ្ជូន | -១,៤ | +២,៦ |
| ៨-គមនាគមន៍ | -០,៣ | -០,៦ |
| ៩-ការកំសាន្ត និងវប្បធម៌ | -០,៣ | +១,៣ |
| ១០-ការសិក្សា | ០,០ | +០,៤ |
| ១១-ភោជនីយដ្ឋាន | +០,៦ | +៦,៣ |
| ១២-ទំនិញ និងសេវាកម្មផ្សេងៗ | -០,៣ | +១,៧ |

---

[១] ការធ្វើចំណោលដល់ខែធ្នូ ឆ្នាំ២០១៨÷ គឺជាការធ្វើចំណោលដោយយោងលើអត្រាកំណើនជាមធ្យមប្រចាំខែ (month on month) នៃសន្ទស្សន៍ថ្លៃទំនិញ ក្នុងរយៈពេល ៣ឆ្នាំ ចុងក្រោយ។

| តារាងបម្រែបម្រួលសន្ទស្សន៍ថ្លៃម្ហូបអាហារសំខាន់ៗ | | | | | | |
|---|---|---|---|---|---|---|
| មុខទំនិញ | ធៀបនឹងខែមុន (%) | | | ធៀបនឹងឆ្នាំមុន (%) | | |
| | ២០១៨ | | | ២០១៨ | | |
| | កញ្ញា | តុលា | វិច្ឆិកា | កញ្ញា | តុលា | វិច្ឆិកា |
| អង្ករ | +០,១ | +០,២ | -០,៣ | +២,៧ | +២,៩ | +២,៣ |
| សាច់គោ | +០,២ | -០,១ | ០,០ | +២,១ | +២,២ | +១,៨ |
| សាច់មាន់ | ០,០ | +០,២ | +០,៤ | +២,០ | +១,៧ | +២,១ |
| សាច់ទា | +០,១ | +០,៧ | +០,៣ | +១,៩ | +២,១ | +២,១ |
| សាច់ជ្រូក | +០,៥ | -០,៦ | -១,៨ | +៣,៤ | +៣,៥ | +១,២ |
| ត្រីទឹកសាប និង ត្រីទឹកសមុទ្រ | +០,៥ | +០,១ | -០,៧ | +៣,២ | +៤,១ | +២,២ |
| ក្នុងនោះត្រីស្រស់ | +០,៧ | ០,០ | -១,១ | +៣,២ | +៤,៣ | +១,៧ |
| ផ្លែឈើ | -០,៥ | +០,៨ | +០,១ | +១,៧ | +២,៥ | +៣,០ |
| ផ្លែឈើស្រស់ | -០,៧ | +០,៩ | +០,១ | +១,៦ | +២,៥ | +៣,០ |
| បន្លែ | +១,៥ | +០,៥ | -០,៩ | +៤,៣ | +៥,៩ | +៤,៩ |
| បន្លែជាស្លឹក | +១,៨ | +១,៥ | -១,៤ | +៧,៥ | +១០,៦ | +៧,៧ |
| បន្លែជាផ្លែ | +២,៨ | -០,៤ | -០,៦ | +៥,៧ | +៥,៤ | +៦,៤ |

## ខ/ អតិផរណាប្រចាំឆ្នាំរបស់ប្រទេសមួយចំនួន

| តារាង ៣÷ អតិផរណាចុងឆ្នាំ (Year on Year) គិតជា % | | | | | | |
|---|---|---|---|---|---|---|
| ប្រទេស | ២០១៧ | | | ២០១៨ | | |
| | កញ្ញា | តុលា | វិច្ឆិកា | កញ្ញា | តុលា | វិច្ឆិកា |
| ប្រទេសកម្ពុជា | 2.7 | 2.1 | 2.3 | 2.6 | 3.1 | 2.5 |
| ប្រទេសវៀតណាម | 3.4 | 3.0 | 2.6 | 4.0 | 3.9 | 3.5 |
| ប្រទេសថៃ | 0.9 | 0.9 | 0.99 | 1.3 | 1.2 | 0.9 |
| ប្រទេសម៉ាឡេស៊ី | 4.3 | 3.7 | 3.4 | 0.3 | 0.6 | 0.2 |
| ប្រទេសឥណ្ឌូនេស៊ី | 3.7 | 3.6 | 3.3 | 2.9 | 3.2 | 3.2 |
| ប្រទេសហ្វីលីពីន | 3.1 | 3.5 | 3.3 | 6.7 | 6.7 | 6.0 |
| ប្រទេសចិន | 1.6 | 1.9 | 1.7 | 2.5 | 2.5 | 2.2 |
| ប្រទេសកូរ៉េខាងត្បូង | 2.1 | 1.8 | 1.3 | 1.9 | 2.0 | 2.0 |
| ប្រទេសជប៉ុន | 0.7 | 0.2 | 0.6 | 1.2 | 1.4 | 0.8 |

ប្រភពទិន្នន័យ
(១) ប្រទេសកម្ពុជា គឺពីវិទ្យាស្ថានជាតិស្ថិតិ(NIS)
(២) ប្រទេសផ្សេងៗទៀត គឺពីគេហទំព័រ http://www.tradingeconomics.com;

<u>កំណត់សម្គាល់</u>

ការចងក្រងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) នៅភ្នំពេញ÷

- ថ្លៃទំនិញដែលត្រូវបានជ្រើសរើសមានចំនួន ២៥៩មុខ
- ថ្លៃមុខទំនិញភាគច្រើនត្រូវបានប្រតិបត្តិការប្រមូលពីផ្សារចំនួន ៥
- ជាទូទៅថ្លៃត្រូវបានប្រមូលពីតូបគំរូចំនួន ៤ក្នុងផ្សារនីមួយៗ
- សម្រាប់មុខទំនិញដែលមិនដាក់លក់នៅទីផ្សារ ថ្លៃត្រូវបានប្រមូលពីតូបនៅជិតៗផ្សារ
- សន្ទស្សន៍ថ្លៃនៃមុខទំនិញត្រូវបានចងក្រងតាមមធ្យមភេខាគណិតសាស្ត្រ (geometric average)

ប្រភព÷ ក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ)

***រៀបចំនិងធ្វើចំណោលដោយ***

***នាយកដ្ឋានស្ថិតិ និងវិភាគសេដ្ឋកិច្ច***

***អគ្គនាយកដ្ឋានគោលនយោបាយ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ***

*ព័ត៌មានផ្សេងៗ សូមទាក់ទងក្រុមការងារ*

*ទូរស័ព្ទលេខ÷ (+៨៥៥) ២៣ ៤២៧ ៩១៣, (+៨៥៥) ៧៧ ៨៨ ៩៩ ៩២*

*ម៉ោងធ្វើការ÷ ៧: ០០ ដល់ ១១: ០០ព្រឹក និង ២: ០០ ដល់ ៥: ០០រសៀល*

*កំណត់សម្គាល់÷*

*ចំពោះមតិដែលបានបង្ហាញក្នុងរបាយការណ៍នេះគឺជាការយល់ឃើញរបស់ក្រុមការងារនៃអគ្គនាយកដ្ឋាន។*

*ការផ្សព្វផ្សាយនេះមិនស្តែងពីការយល់ឃើញរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬរាជរដ្ឋាភិបាលកម្ពុជានោះទេ។*